## សម្រេច

**មាត្រា ១** .- បង្កើតស្ថានឯកអគ្គរាជទូតកម្ពុជា ប្រចាំសាធារណរដ្ឋកូរ៉េ ដោយមាននិវេសនដ្ឋាន នៅក្រុងសេអ៊ូល ។

**មាត្រា ២** .- ស្ថានឯកអគ្គរាជទូតនេះ ត្រូវដឹកនាំដោយប្រធានបេសកកម្មទូតម្នាក់ ដែលមានឋានៈជាឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាព ។

**មាត្រា ៣** .- សមាសភាពមន្ត្រីការទូតផ្សេងទៀត មន្ត្រីបច្ចេកទេស និងបុគ្គលិកសេវា នឹងត្រូវកំណត់តាមតំរូវការនៃការងារជាក់ស្តែង ។

**មាត្រា ៤** .- ប្រព័ន្ធហិរញ្ញកិច្ចសំរាប់មន្ត្រីការទូត មន្ត្រីបច្ចេកទេស និងបុគ្គលិកសេវា នៃស្ថានឯកអគ្គរាជទូតនេះ នឹងស្ថិតក្នុងប្រភេទ " ខ " ។

**មាត្រា ៥** .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះ ហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

* * *

# អនុក្រឹត្យ លេខ ១៤ អនក្រ.បក

## ស្តីពីការបង្កើត

## គណៈកម្មាធិការជាតិសំរបសំរួលគំរោង

## សំរាប់កម្មវិធីស្តារបន្ទាន់នូវគ្រោះមហន្តរាយនានា

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-យោងតាមការងារចាំបាច់ និងបន្ទាន់ចំពោះមុខរបស់រាជរដ្ឋាភិបាល

**សំរេច**

**មាត្រា ១ ._**

ចាត់តាំងគណៈកម្មាធិការជាតិសំរបសំរួលគំរោងសំរាប់កម្មវិធីស្តារបន្ទាន់ នូវគ្រោះមហន្តរាយ ដើម្បីរៀបចំសំរបសំរួល និងដោះស្រាយស្តារការខូចខាតបណ្តាលមកពីគ្រោះមហន្តរាយនានា ហៅថា គណៈកម្មាធិការជាតិសំរបសំរួលគំរោង (NPCC) ។

**មាត្រា ២ ._**

គណៈកម្មាធិការជាតិនេះ មានសមាសភាពដូចតទៅ :

| | | |
|---|---|---|
| ១-ឯកឧត្តម **ឆាយ ថន** | រដ្ឋមន្ត្រី ក្រសួងផែនការ | ប្រធាន |
| ២-ឯកឧត្តម **សួស សុមេត** | ឧត្តមទីប្រឹក្សាសេដ្ឋកិច្ចជាតិ | ទីប្រឹក្សា |
| ៣-ឯកឧត្តម **ស៊ី ម៉ានិត** | រដ្ឋលេខាធិការ ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | អនុប្រធាន |
| ៤-ឯកឧត្តម **អ៊ុក រ៉ាប៊ុន** | រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៥-ឯកឧត្តម **អ៊ូ ឱហាត** | រដ្ឋលេខាធិការ ក្រសួងផែនការ | អនុប្រធានអចិន្ត្រៃយ៍ |
| ៦-ឯកឧត្តម **អ៊ឹម សិទ្ធី** | រដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ៧-ឯកឧត្តម **យឹម នៃលី** | រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ៨-ឯកឧត្តម **ត្រាំ អ៊ីវតឹក** | រដ្ឋលេខាធិការ ក្រសួង សាធារណការ និង ដឹកជញ្ជូន | សមាជិក |

៩-ឯកឧត្តម **អ៊ី គឹមហ៊ាង** រដ្ឋលេខាធិការ ក្រសួងធនធានទឹក និងឧតុនិយម សមាជិក

១០-ឯកឧត្តម ម៉ិន ម៉ិយ អនុរដ្ឋលេខាធិការ ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

១១-ឯកឧត្តម **ឈាង យ៉ាំណារ៉ា** អគ្គលេខាធិការ គជនា សមាជិក

**មាត្រា ៣ .-**

គណៈកម្មាធិការជាតិនេះ មានភារកិច្ច :

ក-លើកឡើងគោលនយោបាយ និងផ្តល់ការណែនាំ សំរាប់សកម្មភាព ស្តារ និងត្រួតពិនិត្យការអនុវត្តន៍គំរោង

ខ-ជួយរាល់សកម្មភាពនៃការអនុវត្តន៍គំរោង ក្នុងការស្តារឡើងវិញ ប្រសិនបើមានការចាំបាច់

គ-សំរបសំរួលរាល់គំរោង និងសកម្មភាពដែលឧបត្ថម្ភ ឬផ្តល់មូលនីធិ ដោយគ្រប់ភ្នាក់ងារ និងប្រទេសផ្តល់ជំនួយ

ឃ-ពិនិត្យ និងអនុម័តលើកម្មវិធីការងារ និងធ្វើរបាយការណ៍ អំពីការងាររីកចំរើនរបស់ភ្នាក់ងារអនុវត្តគំរោងស្តារឡើងវិញ

ង-ធ្វើរបាយការណ៍ ស្តីពីលទ្ធផល នៃការអនុវត្តន៍គំរោងតាមដំណាក់កាលនីមួយៗ ជូនរាជរដ្ឋាភិបាល ។

**មាត្រា ៤ .-**

គណៈកម្មាធិការជាតិសំរបសំរួលគំរោង មានសិទ្ធិបង្កើតលេខាធិការដ្ឋានមួយ សំរាប់ជំនួយការងារ ។

-លេខាធិការដ្ឋាននេះ មានទីតាំងនៅក្រសួងផែនការ ក្រោមការគ្រប់គ្រង និងដឹកនាំដោយឯកឧត្តម **អ៊ី ឌិហាត** អនុប្រធានអចិន្ត្រៃយ៍ នៃគណៈកម្មាធិការជាតិនេះ ហើយមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងផែនការ ។

**មាត្រា ៥ .-**

សេចក្តីសំរេចលេខ ៦១ សសរ ចុះថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០០០ ស្តីពីការចាត់តាំងភ្នាក់ងារប្រតិបត្តិ ដើម្បីសំរបសំរួលជាមួយធនាគារអភិវឌ្ឍន៍អាស៊ី ក្នុងកិច្ចការហិរញ្ញប្បទានសំរាប់

សង្គ្រោះបន្ទាន់ ដែលបណ្តាលមកពីគ្រោះទឹកជំនន់ ឆ្នាំ ២០០០ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៦ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រី ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងឯកឧត្តម ដូចមានចែងឈ្មោះក្នុងមាត្រា២ ខាងលើ ត្រូវទទួលអនុវត្តឱ្យមានប្រសិទ្ធភាពអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

* * *

## អនុក្រឹត្យ លេខ ១៥ អនក្រ.បក

## ស្តីពី

## ការធ្វើវិសោធនកម្មលើមាត្រា ៣១ នៃអនុក្រឹត្យ ស្តីពីអាករតំលៃបន្ថែម លេខ ១១៤ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៩

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ